គោលលទ្ធិ និងសេចក្ដីសញ្ញា ១០១

# រឿងប្រៀបធៀបពីបុរសត្រកូលខ្ពស់ ៖ មេរៀនស្ដីពីការគោរពប្រតិបត្តិ

គោលលទ្ធិ និងសេចក្ដីសញ្ញា ១០១:៤៣–៦២ បង្ហាញពីរឿងប្រៀបធៀបមួយដែលបានផ្ដល់ឲ្យពួកបរិសុទ្ធ និងពន្យល់ពីមូលហេតុដែលពួកគេត្រូវបានបណ្ដេញចេញពីរដ្ឋមិសសួរី ។

## តើខ្ញុំដែលធ្លាប់សង្ស័យពីបទបញ្ញត្តិរបស់ព្រះដែរឬទេ ?

តើបងប្អូនដូចជាពួកអ្នកបម្រើនេះដែរ ធ្លាប់ឆ្ងល់ទេថាតើបទបញ្ញត្តិមួយពិតជាចាំបាច់មែនឬ ? រឿងប្រៀបធៀបនេះបង្រៀនយើងថា បទព្រះបញ្ញត្តិរបស់ព្រះអម្ចាស់ការពារយើង និងជួយយើងឲ្យរស់នៅក្នុងជីវិតដែលរីករាយ ( សូមមើលផងដែរ ម៉ូសាយ ២:៤១; គោលលទ្ធិ និងសេចក្ដីសញ្ញា ៨២:៨–១០ ) ។

តើយើងអាចធ្វើអ្វីបានខ្លះ ប្រសិនបើយើងគិតថាបទបញ្ញត្តិមួយពុំចាំបាច់នោះ ?

- សូមសិក្សាប្រធានបទនោះ និងអធិស្ឋានដើម្បីទូលសូមព្រះអម្ចាស់ជួយយើងឲ្យ « មានអារម្មណ៍ថា ការណ៏នោះត្រឹមត្រូវ » ( គោលលទ្ធិ និងសេចក្ដីសញ្ញា ៩:៨ ) ។
- ចងចាំពីពេលវេលានៅអតីតកាលនៅពេលការគោរពប្រតិបត្តិនាំមកនូវពរជ័យ ។[១]
- ប្រព្រឹត្តដោយសេចក្ដីជំនឿ ដោយការទុកចិត្តថាយើងនឹងយល់ « ក្រោយពីការសាកល្បងសេចក្ដីជំនឿរបស់ [ យើង ] សិន » ( អេធើរ ១២:៦ ) ។



ក្នុងរឿងប្រៀបធៀបនេះ អ្នកបម្រើចាប់ផ្ដើមសង់ប៉មមួយ ប៉ុន្តែបន្ទាប់មកសម្រេចចិត្តថា « មិនត្រូវការ » ប៉មនេះឡើយ ( គោលលទ្ធិ និងសេចក្ដីសញ្ញា ១០១:៤៩ ) ។ ប៉ុន្តែដោយសារពួកគេពុំបានសង់ប៉មនេះ នោះពួកគេពុំមានអ្វីព្រមានប្រាប់ដល់ពួកគេនៅពេលសត្រូវឈ្លានពានចូល និងបំផ្លាញចម្ការទំពាំងបាយជូរឡើយ ។

*បុរស **ត្រកូលខ្ពស់** បញ្ជាដល់ពួកអ្នកបម្រើរបស់គាត់ឲ្យដាំចម្ការទំពាំងបាយជូរ និងដាំដើមឈើជារបងព័ទ្ធជុំវិញដើមឈើ និងប៉មដើម្បីអ្នកយាមអាចត្រួតពិនិត្យមើលដី ។*

***ពួកអ្នកបម្រើ** ដាំចម្ការទំពាំងបាយជូរ និងបានដាំដើមឈើធ្វើជារបង ប៉ុន្តែសម្រេចចិត្តថាពុំសង់ប៉មឡើយ ។*

*សត្រូវ **ដែលនៅទីកំបាំង** បានបំផ្លាញចម្ការទំពាំងបាយជូរនេះ ។*

**កំណត់ចំណាំ**

១. សូមមើល នែល អិល អាន់ឌើរសិន « ការចងចាំខាងវិញ្ញាណដ៏មានអត្ថន័យ » *Liahona* ខែ ឧសភា ឆ្នាំ ២០២០ ទំព័រ ១៨–២២ ។

រចនារូបភាពដោយ ប៊ែន ស៊ីម៉ុនសិន